ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
លេខៈ ១៥១៦/២០ ក.អ.ជ

ថ្ងៃសុក្រ ៥ កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០

# របាយការណ៍
# វឌ្ឍនភាពការងារប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០២០
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១.សេចក្តីផ្តើម

ក្នុងខែវិច្ឆិកា ឆ្នាំ ២០២០ តំបន់ជនបទ មួយចំនួនធំនៃប្រទេសកម្ពុជាត្រូវបានលិចលង់ដោយជំនន់ទឹកភ្លៀងកាលពីខែតុលា ត្រូវបានរាជរដ្ឋាភិបាលកំពុង ខិតខំប្រឹងប្រែងដោះស្រាយបញ្ហាការលំបាកផ្សេងៗក្នុងជីវភាពរស់នៅរបស់ប្រជាជនជនបទក្រោយទឹកជំនន់ ក្នុងនោះថ្នាក់ដឹកនាំ ក្រសួងអភិវឌ្ឍន៍ជនបទកំពុងចូលរួមចំណែកយ៉ាងសកម្មជាទីបំផុត ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនរួមមានការជួសជុល និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ ដូចជា ផ្លូវជនបទ សំណង់សិល្បការ្យផ្សេងៗ ស្ពានអណ្តូងទឹក ស្រះទឹក សាងសង់បង្គន់អនាម័យ ដែលរងការខូចខាតដោយសារទឹកជំនន់ ផ្តល់ស្បៀង និងសម្ភារចាំបាច់មួយចំនួនសម្រាប់បង្កាជំងឺកូវីដ-១៩ ។ល។ បានទាន់ពេលវេលាតាមបណ្តារាជធានី ខេត្តដែលរងការខូចខាតដោយជំនន់ទឹកភ្លៀង ។ ក្នុងខែវិច្ឆិកានេះដែរក៏មានផ្ទុះឡើងនូវព្រឹត្តិការណ៍រាតត្បាតជម្ងឺកូវីដ-១៩ ចំនួន ០២ ដង ក្នុងនោះ មាន "ព្រឹត្តិការណ៍ ៣ វិច្ឆិកា" និង "ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា" ដែលបានជះឥទ្ធិពលដល់ជីវភាពរស់នៅរបស់សហគមន៍ជនបទបន្ថែមពីជំនន់ទឹកភ្លៀង តែទោះជាមានព្រឹត្តិការណ៍ទាំងពីរនេះក្តី ក៏រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការចាត់វិធានការទប់ស្កាត់បានល្អប្រសើរផងដែរ។ ក្រៅពីការងារចុះបំពេញបេសកកម្មនៅមូលដ្ឋានជនបទរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការជំនាញក៏នៅមានសកម្មភាពសំខាន់មួយទៀតគឺការបន្តរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ ២០២១-២០៣០ ដែលកំពុងសកម្មចូលរួមពិភាក្សាយ៉ាងផុសផុលតាមរយៈប្រព័ន្ធវីដេអូអនឡាញពីមន្ត្រីជំនាញ និងថ្នាក់ដឹកនាំក្រសួង ។ លទ្ធផលក្នុងខែវិច្ឆិកា ឆ្នាំ២០២០ ក្រសួងសម្រេចបានដូចខាងក្រោមៈ

## ២.វឌ្ឍនភាព

### ២.១. លទ្ធផលរួមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ការអនុវត្តផែនការសកម្មភាពទូទាំងប្រទេសសម្រេចបានប្រមាណជា ៩០% នៃផែនការសកម្មភាពប្រចាំឆ្នាំ ២០២០ គិតមកដល់ចុងខែវិច្ឆិកា នេះ ។



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

## ២.២.លទ្ធផលរបស់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ

### ២.២.១.ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ ២០២០ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៥១៩ នាក់ (ស្រី ៤១១ នាក់) ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែតុលា គឺមានការកើនឡើង ចំនួន ០១ នាក់ ដោយសារការទទួលក្របខណ្ឌចូល។ ក្រសួងបានទទួលលិខិតចូលចំនួន ១៤៣ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១៤៩ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ១៣ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ១៤៨ ច្បាប់ ។

### ២.២.២.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែវិច្ឆិកា នេះក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២០ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ៣៤ ៤៥៨ ៩២០ ៨៩៧ រៀលស្មើនឹង ១៧,៣៤% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ២៣ ២២៦ ៣៦៨ ០០០ រៀលស្មើនឹង ១២,២២% នៃច្បាប់ថវិកា ។

### ២.២.៣. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ចូលរៀនវគ្គបណ្តុះបណ្តាលស្តីពី "មូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Concepts of Economic and Finance and KPIs Preparation for Public Financial Management) បង្ហាញដោយសាលាគោលនយោបាយសាធារណៈ លីក្វាន់យូ នៃសាកលវិទ្យាល័យសឹង្ហបូរី រយៈពេល ០៣ ថ្ងៃ រៀបចំដោយក្រុមការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរៀនវគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) : បទពិសោធន៍ប្រទេសចិន ដែលរៀបចំឡើងដោយ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយវិទ្យាស្ថានហិរញ្ញវត្ថុ និងអភិវឌ្ឍន៍អាស៊ី បាស៊ីហ្វិក នៃទីក្រុងសៀងហៃ សាធារណៈរដ្ឋប្រជាមានិតចិន រយៈពេល ០២ ថ្ងៃ តាមប្រព័ន្ធអនឡាញ
- រៀបចំផែនការសូចនាករសមិទ្ធកម្មគន្លឹះសម្រាប់អនុវត្ត MAP4 ដោយរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ។

### ២.២.៤. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- ចូលរួមកិច្ចប្រជុំលើកទី ១៨ នៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។

### ២.២.៥. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- បន្តចូលរួមពិភាក្សាខ្លឹមសារគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ ២០២១-២០៣០ ក្នុងជំពូកទី១ ចំនួន ៥ ផ្នែក

- បានរៀបចំសិក្ខាសាលាស្តីពី ការស្វែងយល់ការងារអភិវឌ្ឍន៍នៅមូលដ្ឋាន លើប្រធានបទសមិទ្ធផល តម្រូវការ និងប្រសិទ្ធភាពតាមតំបន់ចំនួន ៥ លើកនៅទីស្តីការក្រសួង
- បានរៀបចំកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការចំនួន ០២ គឺ អង្គការកម្មវិធីអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍(SADP) និងអង្គការមូលនិធិនៃក្តីសង្ឃឹម
- បានផ្តល់លិខិតគាំទ្រអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការស្ម័គ្រចិត្តកសាងកម្ពុជា
- បានផ្តល់លិខិតគាំទ្របន្តអនុស្សរណៈនៃការយោគយល់គ្នារវាងអង្គការ World Hope International ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ ។

### ២.២.៦. ការងារអធិការកិច្ច និងសវនកម្ម

- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការបស់រដ្ឋការិយបរិច្ឆេទ២០១៩ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ
- ចុះអង្កេត និងស្រាវជ្រាវតាមបណ្តឹងរបស់មន្ត្រីរាជការ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី ។

### ២.២.៧. ការងារអភិវឌ្ឍន៍ផ្លូវជនបទ និងមន្ទីរពិសោធន៍

- គម្រោងថែទាំខួប ឆ្នាំ ២០២០ សរុបចំនួន ៣០ គម្រោង ស្មើនឹង ៥៧ ខ្សែ ប្រវែងសរុប ៤៦៣,៤២ គ.ម លូមូល ៦០ កន្លែង និងលូប្រអប់ ០២ កន្លែង សម្រេចលទ្ធផលគិតជាមធ្យមបាន ១០០%
- គម្រោងថែទាំប្រចាំ ឆ្នាំ ២០២០ សរុបចំនួន ៣៨ គម្រោង ស្មើនឹង ២៩៨ ខ្សែ ប្រវែងសរុប ២ ៨១៣,៧៤ គ.ម លូមូល ០១ កន្លែង និងស្លាកសញ្ញាចរាចរចំនួន ២ ១៥២ ស្លាក សម្រេចលទ្ធផលគិតជាមធ្យមបាន ៩០%
- ការងារស្តាបនា កែលម្អ និងជួសជុល ឆ្នាំ ២០២០ មាន ៩៧ គម្រោង ប្រវែងសរុប ៧២៤,៩១ គ.ម សម្រេចបានលទ្ធផលជាមធ្យម ៧៨ %
- គម្រោងការងារជួសជុលបន្ទាន់ កំពុងដំណើរការឯកសារចំនួន ៤៣ គម្រោង សម្រេចលទ្ធផលគិតជាមធ្យមបាន ១០០%
- ចុះត្រួតពិនិត្យ និងវាយតម្លៃគម្រោង ចំនួន ១៨ គម្រោង
- ចុះប្រគល់ទទួលគម្រោង ចំនួន ២១ គម្រោង
- ទទួលសំណាកគំរូពីស្ថាប័ននានា ចំនួន ៤០ សំណាក
- សំណាកសម្រេចបានក្នុងការធ្វើពិសោធន៍ ចំនួន ៣៩ សំណាក

- បានផ្តល់ការបណ្តុះបណ្តាលជំនាញពិសោធន៍ដី បេតុង ដែក និងពិសោធន៍កៅស៊ូដល់និស្សិតបំពេញកម្មសិក្សាចំនួន ០៥ រូប មកពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។

**២.២.៨. ការងារផ្គត់ផ្គង់ទឹកជនបទ**

- បានខួងអណ្តូងស្នប់អាហ្វ្រីដេវ ចំនួន ២៥ អណ្តូង នៅខេត្តប៉ៃលិន ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប
- បានចុះស្រង់ទិន្នន័យអណ្តូង ស្រះទឹក និងប្រភពទឹកដែលបានលិចដោយទឹកជំនន់ ចំនួន ០៦ ស្រុក ស្មើនឹង ១៩ ឃុំ មានអណ្តូងស្នប់ ចំនួន ២៩៣ អណ្តូង អណ្តូងលូ ចំនួន ១២៩ អណ្តូង និងស្រះចំនួន ០៤ ស្រះ នៅខេត្តសៀមរាប
- បានបើកសិក្ខាសាលាផ្សព្វផ្សាយការប្រើប្រាស់ និងបរិភោគទឹកប្រកបដោយសុវត្ថិភាព ចំនួន ០១ វគ្គ នៅខេត្តប៉ៃលិន ។

**២.២.៩. ការងារថែទាំសុខភាព និងអនាម័យជនបទ**

- បានផ្តល់ចានបង្គន់តាមផ្ទះឯកជន ចំនួន ៥៥ ខ្នងផ្ទះ នៅខេត្តកែប និងខេត្តស្វាយរៀង
- បានអប់រំអនាម័យប្រជាពលរដ្ឋ ចំនួន ៣៨ នាក់ នៅខេត្តកំពង់ចាម
- បានចុះអប់រំផ្សព្វផ្សាយអនាម័យតាមសហគមន៍ ដោយផ្តោតសំខាន់លើអនាម័យលាងសម្អាតដៃដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីដ-១៩
- បានបើកវគ្គបណ្តុះបណ្តាលស្តីពីការផ្ទៀងផ្ទាត់ភូមិ ODF នៅខេត្តកំពង់ឆ្នាំង ។

**២.២.១០. ការងារអភិវឌ្ឍន៍សហគមន៍**

- ចូលរួមសម្ពោធដាក់អោយប្រើប្រាស់យុទ្ធសាស្ត្រជាតិស្តីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី ២ ឆ្នាំ ២០១៩-២០២៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី
- បើកសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពីគោលគំនិតនៃការអភិវឌ្ឍសហគមន៍នៅខេត្តព្រៃវែង
- រៀបចំរបាយការណ៍ សមិទ្ធផលគម្រោងអភិវឌ្ឍន៍មូលដ្ឋាន គម្រោងសន្តិសុខស្បៀងជាលក្ខណៈគ្រួសារ និងគម្រោងអប់រំក្រៅប្រព័ន្ធ រយៈពេល ១០ ឆ្នាំ (២០១០-២០២០)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ចំនួន ០២ វគ្គ មានសិក្ខាកាម ៤៦ នាក់ ស្រី ៣០ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានបន្តធ្វើការផ្សព្វផ្សាយជ្រើសរើសសិស្សឲ្យចូលរៀនវគ្គបណ្តុះបណ្តាល ឆ្នាំ២០២០ ។

**២.២.១១. ការងារបណ្តុះបណ្តាល**

- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៥៣ នាក់ ស្រី ១១ នាក់
- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ៦៧ នាក់ ស្រី ១៣ នាក់

- បានរៀបចំធ្វើបច្ចុប្បន្នភាពតារាងទិន្នន័យបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា
- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១៣ ខេត្ត បានរៀបចំ និងកែសម្រួលឯកសារពាក់ព័ន្ធមួយចំនួន រៀបចំគម្រោងផែនការថវិកាសម្រាប់ឆ្នាំ២០២១ ព្រមទាំងបន្តការផ្អាកជាបណ្តោះអាសន្នលើការងារបណ្តុះបណ្តាល ដោយសារការបញ្ហាជំងឺកូវីដ-១៩ ។ ដោយឡែកសម្រាប់មជ្ឈមណ្ឌលមួយចំនួន បានបើកបន្តឡើងវិញនូវវគ្គបណ្តុះបណ្តាលចំនួន ២៨ វគ្គ មានសិក្ខាកាមសរុប ៥៩០ នាក់ (ស្រី ២៩០ នាក់) ក្នុងនោះ ៖
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០៧ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៣៥ នាក់ (ស្រី ៦៥ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០៤ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៥ នាក់ (ស្រី ៤៤ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០២ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៥ នាក់ (ស្រី ៤២ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០៤ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៥ នាក់ (ស្រី ៣៣ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០២ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ២៥ នាក់ (ស្រី ២០ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានបន្តបើកវគ្គបណ្តុះបណ្តាល ចំនួន ០៣ វគ្គដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៦៥ នាក់ (ស្រី ៣៥ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានបើកវគ្គបណ្តុះបណ្តាល ចំនួន ០២ វគ្គដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៣៥ នាក់ (ស្រី ២១ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ បានបើកវគ្គបណ្តុះបណ្តាល ចំនួន ០១ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ២៥ នាក់ (ស្រី ០៤ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តសៀមរាប បានបើកវគ្គបណ្តុះបណ្តាល ចំនួន ០១ វគ្គដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៣០ នាក់ (ស្រី ១៤ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ឆ្នាំង បានបើកវគ្គបណ្តុះបណ្តាល ចំនួន ០២ វគ្គដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៥០ នាក់ (ស្រី ១២ នាក់) ។

### ២.២.១២. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពុងអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយ សហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុបចំនួន ៤ ២០៤ ៦០៨ ២៣៥ រៀល (បួនប៊ីលានពីររយបួនលានប្រាំមួយរយប្រាំបីពាន់ពីររយសាមសិបប្រាំរៀល) ស្មើនឹង ១ ០៧០ ៣៧៨,០២ ដុល្លារអាមេរិក (មួយលានចិតសិបពាន់បីរយចិតសិបប្រាំបីដុល្លារនិង

ពីរសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ២៣៧ នាក់ នៅភូមិគោលដៅ ចំនួន ១៩១ ភូមិ ៧៤ ឃុំ ៣៣ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥ ។

**២.២.១៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

- ចូលរួមកិច្ចប្រជុំអនុក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពី ការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីធនធានពន្ធុ (ABS SubTWG) លើកទី២
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការត្រួតពិនិត្យអំពីការចំណាយលើផ្នែកជីវៈចម្រុះ និងការវាយតម្លៃតម្រូវការហិរញ្ញវត្ថុ នៃគម្រោងគំនិតផ្តួចផ្តើមហិរញ្ញប្បទានជីវៈជម្រុះ (BIO FIN) ។

**២.២.១៤.ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤**

ក្នុងខែវិច្ឆិកា ឆ្នាំ ២០២០ នេះ លេខាធិការដ្ឋានក្រុមការងារចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានចំនួន ១៦ ករណី ក្នុងនោះតាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រសួងដោះស្រាយបានចំនួន ០២ ករណី ។

**២.២.១៥. ការងារយេនឌ័រ**

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសមត្ថភាពយេនឌ័រ និងផែនការយុទ្ធសាស្រ្តនារីរតនៈទី៥ ឆ្នាំ ២០១៩-២០២៣
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីផលប៉ះពាល់នៃកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ។

**២.២.១៦. ការងារប្រយុទ្ធនឹងជំងឺអេដស៍**

- ប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០២១ ។

**២.៣. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី**

**២.៣.១. គម្រោងកែលម្អផ្លូវជនបទ ដំហាន ២**

គិតត្រឹមដំណាច់ខែវិច្ឆិកានេះ គម្រោងសម្រេច៖

- បានបញ្ចប់ការសាងសង់ផ្លូវ នៅខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដែលមានប្រវែងសរុប ៥៦១,៣០ គ.ម
- បានបញ្ចប់ការសាងសង់ប្រឡាយទឹកស្រោចស្រពដំណាំ និងមណ្ឌលសុខភាព នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១០៤,០៨ គ.ម សម្រេចបាន ៨៩,៨៥%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៧៨,៩៦%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១២៦,៣០ គ.ម សម្រេចបាន ៨៥,១៦%

- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៩១,៨៩%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ ខ្សែ ប្រវែង ១១៣,៤០ គ.ម សម្រេចបាន ៩២,៦៨% ។

**២.៣.២. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងបានទទួលការអនុម័តចំនួន ២ ៦៧៣ គម្រោង ប្រវែង ២ ៤០៧ ៨៥៨ ម៉ែត្រ បាន និងកំពុងអនុវត្តចំនួន ១ ៤៥៣ គម្រោង ប្រវែង ១ ៣២៤ ៩០៦ ម៉ែត្រ ក្នុងខេត្តគោលដៅចំនួន ១៧ ក្នុងនោះបានបញ្ចប់ការងារ ចំនួន ១៣៣ គម្រោង ប្រវែង ១២៥ ៧៦៤ ម៉ែត្រ ។

**២.៣.៣.គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង (Mekong Lancang Cooperation)**

- រៀបចំឯកសារសម្រាប់អនុវត្តផែនការសកម្មភាពជំហានទី២ ។

**២.៣.៤. គម្រោងសហប្រតិបត្តិការមេគង្គ-គង្គា**

- កំពុងដាក់ស្នើថវិកាជំហានទី២ ។

**២.៣.៥. គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍**

គិតត្រឹមខែវិច្ឆិកានេះ គម្រោងសម្រេច៖

- បាន និងកំពុងសាងសង់ផ្លូវ ចំនួន ០៧ ខ្សែ ប្រវែង ៤៩,៨៩គីឡូម៉ែត្រ នៅខេត្តកណ្ដាល ដោយសម្រេចបាន ១៤,៨៨%
- បានចុះផ្សព្វផ្សាយលើការងារសង្គម និងបរិស្ថាននៅតាមខ្សែផ្លូវដែលត្រូវសាងសង់ នៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង
- បានទទួលការឯកភាពពីធនាគារពិភពលោក លើរបាយការណ៍វាយតម្លៃឯកសារដេញថ្លៃសាងសង់ផ្លូវកញ្ចប់ទី ៣ ស្ថិតនៅក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប
- បានចេញលិខិតជូនដំណឹងស្ដីពីលទ្ធផលនៃការដេញថ្លៃដល់ក្រុមហ៊ុនទាំង ១៣ ដែលបានចូលរួមការដេញថ្លៃកញ្ចប់ទី ៣
- កំពុងធ្វើការវាយតម្លៃឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនសម្រាប់ការងារ Institutional Strengthening and Capacity Building for Disaster Resiliency of Rural Roads ។

**២.៣.៦. គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ជំហាន ២**

គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទ ជំហាន២ អនុវត្តរយៈពេល ១២ខែ ក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលក្នុងនោះគម្រោងផ្គត់ផ្គង់ទឹកជនបទអនុវត្តនៅខេត្តគោលដៅចំនួន ១០ គឺខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តកំពត ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម និងគម្រោងកែលម្អផ្លូវជនបទជំហាន២ អនុវត្តនៅខេត្តគោលដៅចំនួន ០៦រួមមាន ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកណ្ដាល ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ ។ នៅក្នុងខែវិច្ឆិកានេះ គម្រោងសម្រេច៖

- ជីកអណ្ដូងបានចំនួន ២០ អណ្ដូង

- តម្លើងស្នប់ ចំនួន ៦៤ ស្នប់
- បាន និងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ១១៩,៥៥ គ.ម នៅខេត្តគោលដៅទាំង ០៦ សម្រេចបាន ៣២,៤៩ % ។

**២.៣.៧. គម្រោងពិពិធកម្មកសិកម្មកម្ពុជា**

គម្រោងពិពិធកម្មកសិកម្មកម្ពុជាអនុវត្តរយៈពេល ០៦ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៤ ។ គម្រោងមានគោលបំណង ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍខ្សែច្រវ៉ាក់ផលិតផល កសិកម្មចម្រុះ នៅក្នុងតំបន់ភូមិសាស្ត្រ នៅខេត្តគោលដៅចំនួន ១៣ រួមមាន ខេត្តត្បូងឃ្មុំ ខេត្តកណ្ដាល ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ ។ នៅក្នុងខែវិច្ឆិកានេះគម្រោងសម្រេច៖

- បើកឯកសារដេញថ្លៃចំនួន ០២ គឺ ការផ្គត់ផ្គង់គ្រឿងសង្ហារឹម និងការផ្គត់ផ្គង់ម៉ូតូចំនួន ១៣ គ្រឿង
- រៀបចំផែនការថវិកាសម្រាប់ឆ្នាំ ២០២១
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយគម្រោងពិពិធកម្មកសិកម្មកម្ពុជា នៅថ្នាក់ខេត្តទាំង១២
- មន្រ្តីថ្នាក់ខេត្តបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយគម្រោងពិពិធកម្មកសិកម្មកម្ពុជាថ្នាក់ស្រុកក្នុងខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តកណ្ដាល ។

**២.៣.៧. គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា**

គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា(CSLEP) ជាគម្រោងក្រោមហិរញ្ញប្បទានឥណទានសហប្រតិបត្តិការ ពីធនាគារពិភពលោក និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ០៥ ឆ្នាំ (២០២០-២០២៥) ។ គម្រោងមានគោលបំណងស្ដាបនាផ្លូវក្រាលកៅស៊ូពីរជាន់ ប្រភេទ DBST និងប្រភេទផ្លូវបេតុង នៅខេត្តគោលដៅចំនួន ០៧ រួមមាន ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ ។ ក្នុងខែវិច្ឆិកានេះគម្រោងសម្រេចបាន ៖

- បានប្រមូលទិន្នន័យបច្ចុប្បន្នភាពខ្សែផ្លូវ ដោយផ្អែកលើទីតាំងតំបន់អេកូទេសចរណ៍ទាំង ១៥ នៅ តាមបណ្ដាខេត្តគោលដៅទាំង ០៧ ខេត្ត
- ចុះប្រមូលទិន្នន័យទឹកស្អាតនិងអនាម័យ និងវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម នៅខេត្ត គោលដៅចំនួន ០៣ រួមមាន ខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ និងខេត្តសៀមរាប
- រៀបចំធ្វើផែនការថវិកា និងផែនការលទ្ធកម្មសម្រាប់ឆ្នាំ ២០២១
- រៀបចំកិច្ចសន្យាទីប្រឹក្សាសម្រាប់តួនាទីផ្នែកសង្គម និងបរិស្ថាន
- រៀបចំតារាងតក្ក និងផែនការស្ដីពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់គម្រោងជូនក្រសួងបរិស្ថាន និងធនាគារពិភពលោក ។

## ៣. ទិសដៅបន្ត

### ៣.១. បញ្ហាប្រឈម

- សមត្ថភាពចូលរួមផ្ដល់សេវារបស់វិស័យឯកជននៅមានកម្រិត

- ទម្លាប់សង្គមក្នុងការបន្ទោបង់ពាសវាលពាសកាល មិនទម្លាប់ផឹកទឹកស្អាត និងការលាងដៃឲ្យបានត្រឹមត្រូវ ខ្វះការយល់ដឹង ដែលនាំឲ្យកម្រិតវិនិយោគពីគ្រួសារទាប
- ទីផ្សារអនាម័យនៅមានកម្រិត (បច្ចេកវិទ្យា ផលិតផល ការផ្គត់ផ្គង់បរិក្ខារអនាម័យ)
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- គ.អ.ភ ពុំមានស្នាក់ការសម្រាប់ធ្វើការងារ
- ស្ថាប័ន ឬអង្គការមួយចំនួន មិនបានប្រើប្រាស់ គ.អ.ភ ហើយបានបង្កើតជនបង្គោលផ្សេងៗពី គ.អ.ភ
- កិច្ចសហការជាមួយអង្គការ ដៃគូអភិវឌ្ឍន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត នៅមានកម្រិតនៅឡើយលើវិស័យឥណទានជនបទ និងសកម្មភាពបង្កើនប្រាក់ចំណូលផ្សេងៗ ។

**៣.២. ទិសដៅតាមអង្គភាព**

- បន្តត្រួតពិនិត្យខ្លឹមសារ គោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ ២០២១-២០៣០ របស់ក្រសួងលើជំពូកទី២ ដែលមាន ៥ ផ្នែកធំៗ
- រៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការអនុវត្តផែនការថវិកាឆ្នាំ ២០២០ និងទិសដៅការងារឆ្នាំ ២០២១ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធអនឡាញ
- ត្រៀមរៀបចំផែនការថវិកាតាមកម្មវិធីទាំង ៥ សម្រាប់ឆ្នាំ២០២២
- បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូ និងអង្គការមិនមែនរដ្ឋាភិបាល
- បន្តចុះធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តជំរុញការងារតាមការដ្ឋានសាងសង់ផ្លូវ ដើម្បីបញ្ចប់ការងារឲ្យបានទាន់ពេលវេលា
- បន្តចុះត្រួតពិនិត្យការងារស្ថាបនា និងកែលម្អផ្លូវជនបទ
- អនុវត្តការងារថែទាំ និងជួសជុលផ្លូវនៅតាមបណ្តាខេត្ត
- បន្តការងារបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌផ្លូវ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ទូទាំង ២៥ រាជធានី ខេត្ត
- ផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តការរៀបចំផែនការ និងកិច្ចសហការនានាជាមួយអង្គការដៃគូនានាលើកម្មវិធីលើកកម្ពស់អនាម័យជនបទ
- បន្តសហការសាកល្បងការផ្ទេរមុខងារអនាម័យទៅរដ្ឋបាលថ្នាក់ស្រុកទាំង ១៥ ក្នុងខេត្តគោលដៅទាំង ០៣ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- សិក្សាស្រុកគោលដៅថ្មី និងរៀបចំឯកសារគតិយុត្តសម្រាប់ស្រុកចំនួន ១៥ ដែលត្រូវសាកល្បងផ្ទេរមុខងារអនាម័យ
- ត្រៀមរៀបចំពិនិត្យសារឡើងវិញនូវផែនការសកម្មភាពជាតិជំហានទី១ (២០១៤-២០១៨) និងរៀបចំធ្វើផែនការសកម្មភាពជាតិជំហានទី២ស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យជនបទ (២០១៩-២០២៣)

- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី
- បន្តជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យបង្កើតសហគ្រាសខ្នាតគ្រួសារ និងខ្នាតតូច
- ពង្រឹងការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជាការងារឥណទានសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ ការបណ្តុះបណ្តាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម
- សិក្សាភូមិគោលដៅដើម្បីរៀបចំកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- បន្តការចុះកំណត់អត្តសញ្ញាណ បទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈរបស់ក្រុមជនជាតិដើមភាគតិច ។

## ៤.សេចក្តីសន្និដ្ឋាន

ក្នុងខែវិច្ឆិកា ឆ្នាំ ២០២០ នេះ ក្រោយបញ្ចប់ជំនន់ទឹកភ្លៀង ក្រសួងអភិវឌ្ឍន៍ជនបទ មានសកម្មភាពយ៉ាងមមាញឹកក្នុងការចុះស្រង់ទិន្នន័យខូចខាត និងប៉ះពាល់ដោយទឹកជំនន់ និងចាប់ផ្តើមរៀបចំជួសជុលហេដ្ឋារចនាសម្ព័ន្ធជនបទឡើងវិញ ទន្ទឹមនឹងអនុវត្តផែនការសកម្មភាពចុងឆ្នាំ ២០២០ នេះផង ។

ទោះបីជាមានករណីឆ្លងចូលសហគមន៍នៃកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ទាំងពីរ ខាងលើក៏ដោយ ក៏ក្រសួងនៅតែបន្តធ្វើការប្រជុំ ពិភាក្សាគ្នាតាមប្រព័ន្ធអនឡាញ ដើម្បីដោះស្រាយបញ្ហាដែលនៅសេសសល់បានដែរ ដោយពុំទុកឲ្យស្ទះការងារនោះឡើយ ។

លទ្ធផលក្នុងខែវិច្ឆិកា ឆ្នាំ ២០២០ នេះ កំពុងសកម្មចូលរួមដោះស្រាយបញ្ហាប្រឈមនានានៅតាមជនបទដើម្បីធានាដល់ជីវភាពរស់នៅរបស់ប្រជាជនជនបទដោយសុខសាន្ត និងនៅតែអាចបន្តសកម្មភាពសេដ្ឋកិច្ចគ្រួសារបានដដែល ដោយគ្រាន់តែអនុវត្តវិធាននានារបស់ក្រសួងសុខាភិបាល ៕

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**